សាកលវិទ្យាល័យ COPENHAGEN

# របាយការណ៍ឃ្លាំមើលព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និងព្រៃសង្ឃសហគមន៍រុក្ខាវ័ន។

## របាយការណ៍ឃ្លាំមើល លើកទី២

Argyriou, D.; Theilade, I.; Bori, P. J.

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖
២០២២

កំណែឯកសារ៖
បោះពុម្ពផ្សាយជា ឯកសារ PDF ដែលត្រូវបានដឹងផងដែរថា ជាកំណែនៃកំណត់ត្រា

អាជ្ញាប័ណ្ណឯកសារ៖
CC BY-NC-SA

ការដកស្រង់សម្រាប់កំណែដែលបានបោះពុម្ពផ្សាយ (APA)៖
Argyriou, D., Theilade, I., & Bori, P. J. (២០២២)។ របាយការណ៍ឃ្លាំមើលព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និងព្រៃសង្ឃសហគមន៍រុក្ខាវ័ន។ របាយការណ៍ឃ្លាំមើលលើកទី២។ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុង យុត្តិធម៌បរិស្ថាន សម្រាប់ទាំងអស់គ្នា (CEEJA)។

# របាយការណ៍ឃ្លាំមើលព្រៃឈើ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់ ព្រៃព្រះរកា និង ព្រៃសង្ឃសហគមន៍រុក្ខាវ័ន

CEEJA

អ្នកនិពន្ធ
Argyriou D., Bori P. J., Theilade I.

## របាយការណ៍ឃ្លាំមើល លើកទី២



កម្ពុជាបានបាត់បង់គម្របព្រៃឈើចំនួន ១៤៤,០០០ហិកតា នៅក្នុងឆ្នាំ២០២១

ខ្សែបញ្ជូនថាមពលអគ្គីសនី ធ្វើឱ្យប៉ះពាល់ដល់តំបន់ការពារ និងរបរចិញ្ចឹមជីវិតដែលពឹកផ្អែកលើអនុផលព្រៃឈើ

សំនួរចំពោះការយកចិត្តទុកដាក់របស់កម្ពុជាក្នុងកិច្ចការការពារធនធានធម្មជាតិ

រាជរដ្ឋាភិបាល ត្រូវបញ្ឈប់ការយាយី ទៅលើអ្នកការពារបរិស្ថាន

# ០១ សេចក្តីផ្តើម



## តើ CEEJA ជាអ្វី?

ព្រៃឈើត្រូពិចរបស់ពិភពលោក ស្ថិតនៅក្រោមសម្ពាធជាបន្តបន្ទាប់ ពីការរីករាលដាល់នៃការកាប់ឈើ ដែលជំរុញដោយការពង្រីកផ្ទៃដីកសិពាណិជ្ជកម្ម ប្រតិបត្តិការរុករករ៉ែ វារីអគ្គិសនី និងតម្រូវការសកល សម្រាប់ឈើមានតម្លៃ។ ប្រទេសកម្ពុជាបានរក្សាគម្រប់ព្រៃឈើធម្មជាតិ ជាង៨លានហិកតា កាលពីពីរទសវត្សរ៍កន្លងទៅ។ សព្វថ្ងៃនេះ តំបន់ជាច្រើន ក្នុងចំណោមផ្ទៃដី ៨លានហិកតា ត្រូវបានគ្របដណ្តប់ដោយ វាលដែលគ្មានស្មៅ គ្មានបន្លែ គ្មានសត្វព្រៃ និងគ្មានមនុស្ស។ បើទោះបីជាមានការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ ពីសង្គមស៊ីវិលកម្ពុជាក៏ដោយក៏ប្រទេសនេះ មានអត្រាការកាប់បំផ្លាញព្រៃឈើខ្ពស់បំផុតក្នុងពិភពលោក។ អំពើពុករលួយ កង្វះការអនុវត្តច្បាប់ និងការយាយីឥតឈប់ឈរចំពោះអ្នកការពារបរិស្ថាន ការទប់ស្កាត់ គំនិតផ្តួចផ្តើមការអភិរក្សដោយម្ចាស់ជំនួយ ឧស្សាហកម្មអភិរក្ស និងសង្គមស៊ីវិល។

## ប្រជាពលរដ្ឋជាច្រើនបានចូលរួមក្នុង យុត្តិធម៌បរិស្ថាន ដើម្បីទាំងអស់គ្នា

(CEEJA) គឺជាសកម្មភាពដែលមានរយៈពេល ៥ឆ្នាំ ដើម្បីបង្កើនប្រសិទ្ធភាព នៃការការពារព្រៃឈើនៅកម្រិតមូលដ្ឋាន។

CEEJA ត្រូវបានអនុវត្តដោយ សម្ព័ន្ធនៃអង្គការ Danmission មជ្ឈមណ្ឌលប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) សមាគមបណ្តាញយុវជនកម្ពុជា (CYN) អង្គការស្ពានសន្តិភាព (PBO) អង្គការពន្លកខ្មែរ (PKH) និងសាកលវិទ្យាល័យ Copenhagen។



សម្ព័ន្ធដៃគូ ជាមួយអង្គការសង្គមស៊ីវិលជាច្រើន និងស្ថាប័នអប់រំមួយចំនួន ដែលមានប្រវត្តិសហការគ្នាយ៉ាងយូរ លើការការពារធនធានធម្មជាតិនៅកម្ពុជា។ CEEJA ត្រូវបានអនុវត្តនៅក្នុងតំបន់សំខាន់ចំនួនបី៖ ដែនជម្រកសត្វព្រៃ ព្រៃឡង់ ដែនជម្រកសត្វព្រៃ ព្រះរកា និងដែនជម្រកសត្វព្រៃ សង្ឃសហគមន៍រុក្ខាវ័ន។

## ២១ តុលា



**រូបភាពទី១**
អ្នកដើរល្បាតប្រទះឃើញ
ដើមឈើមួយដើមដួលរលំនៅខេត្តព្រះវិហារ

# បេសកកម្ម របស់យើង

សកម្មភាពនេះ មានគោលបំណងធានាឱ្យប្រជាពលរដ្ឋ ដែលពឹងផ្អែកលើព្រៃឈើ អាចអភិរក្ស និងទទួលបានអត្ថប្រយោជន៍ពីធនធានធម្មជាតិ ដែលព្រៃឈើទាំងនេះផ្តល់ឱ្យ ដោយពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការអនុវត្តសិទ្ធិបរិស្ថានដោយសន្តិវិធី។

យុទ្ធសាស្ត្ររបស់យើងមានចំនួនប្រាំ៖

- ផ្តលការគាំទ្រផ្នែកហិរញ្ញវត្ថុ និងពង្រឹកសមត្ថភាព បណ្តាញព្រៃឈើ
- កសាងប្រព័ន្ធឃ្លាំមើលព្រៃឈើរួមគ្នា ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប (I-FOROS)
- ប្រើប្រាស់យុទ្ធសាស្ត្រផ្សព្វផ្សាយ និងទំនាក់ទំនង ដើម្បីផ្សារភ្ជាប់ទៅកាន់យុវជនកម្ពុជា អំពីយុត្តិធម៌បរិស្ថាន នៅតាមតំបន់ជនបទ និងទីក្រុង
- កសាងសមត្ថភាពបណ្តាញព្រៃឈើ ដើម្បីឱ្យពួកគេ អាចចូលរួមយ៉ាងសកម្មក្នុង ដំណើរការអភិវឌ្ឍន៍គោលនយោបាយ នៅកម្រិតមូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិ
- លើកកំពស់ការផ្សព្វផ្សាយ ពីការងាររបស់យើងតាមរយៈវេទិកាចែករំលែកចំណេះដឹងសកម្ម ដើម្បីចូលរួមយ៉ាងទូលំទូលាយជាមួយសង្គមស៊ីវិលពាក់ព័ន្ធនៅកម្រិតមូលដ្ឋាន និងអន្តរជាតិ។

# ០២ ដែនជម្រកសត្វព្រៃ និងសហគមន៍





ដែនជម្រកសត្វព្រៃ ព្រៃឡង់ ស្ថិតនៅភាគកណ្តាលនៃប្រទេសកម្ពុជា និងជាព្រៃទំនាបបៃតងគ្រប់រដូវកាលធំជាងគេបំផុត នៅក្នុងតំបន់ឥណ្ឌូភូមា ដែលមានជីវៈ ចម្រុះច្រើនសំបូរបែប។ ព្រៃឡង់មានព្រៃឈើជាង ៥០០,០០០ហិកតា និងជាទីកន្លែងដ៏អស្ចារ្យដែល សំបូរទៅដោយប្រភេទរុក្ខជាតិ និងពពួកសត្វជាច្រើនប្រភេទ។ ដែនជម្រកសត្វដែលត្រូវបានប្រកាសជាផ្លូវការ នៅឆ្នាំ២០១៦ ក៏ជាជម្រករបស់ប្រជាជនជាង ២០០,០០០នាក់ រួមមាន សហគមន៍ជនជាតិដើម ភាគតិចកួយ និងប្រជាពលរដ្ឋខ្មែរទូទៅ ដែលភាគ ច្រើនពឹងផ្អែកលើព្រៃឈើទាំងនេះ សម្រាប់របរចិញ្ចឹមជីវិត។ ព្រៃឈើផ្តល់ឱ្យពួកគេនូវ ឈើសម្រាប់សម្ភារៈសំណង់ ប៉ុន្តែក៏មានអនុផលព្រៃឈើ ដូចជា ជ័រ ឱសថបុរាណ និងអាហារផងដែរ។

ព្រៃឡង់ ត្រូវបានហ៊ុំព័ទ្ធដោយ ទីតាំងសម្បទានដីសេដ្ឋកិច្ច (ELCs) ដែលរដ្ឋាភិបាលកម្ពុជាបានផ្តល់សិទ្ធិឱ្យក្រុមហ៊ុនជាច្រើន ដែលមានសិទ្ធិក្នុងការកាប់ឈើ កសិឧស្សាហកម្ម និងការជីកយករ៉ែ។ ឧស្សាហកម្មទាំងនេះជាទៀងទាត់ មិនបានយកចិត្តទុកដាក់លើការកំណត់ទំហំផ្លូវការ នៃបរិវេនសម្បទានដីសេដ្ឋកិច្ចរបស់ពួកគេឡើយ ហើយបន្តសកម្មភាពហួសទៅក្នុងព្រំប្រទល់ នៃដែនជម្រកសត្វព្រៃ។ យោងតាមរបាយការណ៍ ដែលចេញផ្សាយក្នុងឆ្នាំ ២០២០ ដោយកម្មវិធីបរិស្ថាន របស់អង្គការជេស៊ីតសឺវិសកម្ពុជា (JSC) និងបណ្តាញយុវជនកម្ពុជា (CYN) ព្រៃឈើជាង ១០៣,០០០ហិកតា ត្រូវបានកាប់រានដោយខុសច្បាប់ និងបំប្លែងទៅជា ដីចំការដំណាំ និងជាតំបន់តាំងលំនៅឋាន របស់មនុស្ស នៅក្នុងព្រៃឡង់ ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ។[1]

**បណ្តាញសហគមន៍ព្រៃឡង់ (PLCN)** គឺជាបណ្តុំនៃសហគមន៍មូលដ្ឋាន ដែលធ្វើការការពារព្រៃឈើដោយស្ម័គ្រចិត្តតាំពីឆ្នាំ២០០០ ក្នុងគោលបំណងដើម្បី ចងក្រងឯកសារអំពីសកម្មភាពកាប់ឈើខុសច្បាប់ ដែលគំរាមកំហែងដល់ព្រៃឈើ។ PLCN ត្រូវបានទទួលស្គាល់ជាអន្តរជាតិ សម្រាប់កិច្ចខិតខំប្រឹងប្រែងអភិរក្សរបស់ខ្លួន និងទទួលបានពានរង្វាន់បរិស្ថានអន្តរជាតិជាច្រើន។ ប៉ុន្តែសមាជិករបស់ PLCN នៅតែបន្តប្រឈមមុខនឹងការយាយី និងការចាប់ខ្លួនដោយអាជ្ញាធររដ្ឋ។ នៅឆ្នាំ២០២០ PLCN ត្រូវបានហាមឃាត់មិនឱ្យធ្វើសកម្មភាពល្បាតព្រៃ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់។ ការហាមឃាតលើការល្បាតព្រៃ របស់សហគមន៍មូលដ្ឋាននេះ បានបណ្តាលឱ្យមាន ការកាប់ឈើខុសច្បាប់កើនឡើងយ៉ាងឆាប់រហ័ស។

១. របាយការបច្ចេកទេស ស្តីពី ការការពារការផ្លាស់ប្តូរគម្របព្រៃឈើនៅក្នុងតំបន់ការពារព្រៃឡង់របស់កម្ពុជា។ ការសិក្សាមួយ ដែលនិពន្ធដោយកម្មវិធីអេកូឡូស៊ី របស់អង្គការជេស៊ីតសឺវិសកម្ពុជា (JSC) ក្នុងភាពជាដៃគូជាមួយ សមាគមបណ្តាញយុវជនកម្ពុជា (CYN) ខែសីហា ឆ្នាំ២០២០៖ https://preylang.net/wp-content/uploads/2021/03/Forest-Cover-Change-Prey-Lang-Report.pdf

# I. ដែនជម្រកសត្វព្រៃ ព្រៃឡង់




**រូបភាពទី២**

ការចុះល្បាតរបស់សហគមន៍ ក្នុងដែនជម្រកសត្វព្រៃព្រៃឡង់។ ព័ត៌មានភូមិសាស្រ្ត នៅខែធ្នូ ឆ្នាំ២០២១ ទិន្នន័យរូបភាពត្រូវបានទាញ យកពីមន្ទីពិសោធន៍ភព ( Planet Labs)។ ទិន្នន័យឃ្លាំមើលព្រៃឈើ ត្រូវបានបង្ហាញដោយរង្វង់ពណ៌ខុសៗគ្នា ទៅតាមប្រភេទផ្សេងៗគ្នា។ ឧបករណ៍តាមដានការរំខានគម្របព្រៃឈើ (FCDM-រ៉ាដា) ដែលរកឃើញនៅឆ្នាំ២០២១ ត្រូវបានបង្ហាញជាមួយនឹងស្នាមពណ៌ក្រហម ខណៈពេលដែលការផ្លាស់ប្តូរព្រៃឈើសកល (GFC) ឆ្នាំ២០២១ ត្រូវបានបង្ហាញជាមួយស្នាមពណ៌ខៀវ។ ពណ៌ស្វាយដែលត្រួត លើគ្នា គឺជាកន្លែងដែលសំណុំទិន្នន័យទាំងពីរស្របគ្នា។ សម្បទានដីសេដ្ឋកិច្ច (ELCs) ត្រូវបានបង្ហាញដោយពណ៌លឿងទុំ។

- សកម្មភាព
- ការប្រែប្រួលអាកាសធាតុ
- ផ្សេងៗ
- សេចក្តីរាយការណ៍
- ធនធានធម្មជាតិ
- សម្បទានដីសេដ្ឋកិច្ច
- ការបាត់បង់គម្របព្រៃឈើ
- ការរំខានគម្របព្រៃឈើ (២០២១)

ការបាត់បង់គម្រប ព្រៃឈើប្រចាំឆ្នាំ (ហិកតា)[34]

ដែនជម្រកសត្វព្រៃ ព្រៃឡង់




នៅឆ្នាំ២០២១ ដែនជម្រកសត្វព្រៃ ព្រៃឡង់ បានបាត់បង់គម្របព្រៃឈើជាង ១១,១០០ហិកតា ជាការបាត់បង់ខ្ពស់បំផុតក្នុងកំណត់ត្រា។ វាទាក់ទងទៅនឹងការកើនឡើងចំនួន ២២% ចាប់តាំងពីឆ្នាំ២០២០ និងស្មើនឹង ២.៧% នៃការបាត់បង់គម្របព្រៃឈើសរុប។ ចាប់តាំងពីឆ្នាំ២០០០មក ដែនជម្រកសត្វព្រៃ ព្រៃឡង់ បានបាត់បង់ព្រៃឈើចំនួន ៦៧.៤០០ហិកតា ស្មើនឹង ១៦% នៃគម្របព្រៃឈើសរុប។[33]

# ០២



# II. ដែនជម្រកសត្វព្រៃព្រះរកា




រូបភាពទី៤
ការចុះល្បាតរបស់សហគមន៍ នៅក្នុងដែនជម្រកសត្វព្រៃព្រះរកា។ ព័ត៌មានភូមិសាស្ត្រ នៅខែធ្នូ ឆ្នាំ២០២១ ទិន្នន័យរូបភាព ត្រូវបានទាញយកពីមន្ទីពិសោធន៍ភព (Planet Labs)។ ទិន្នន័យឃ្លាំមើលព្រៃឈើ ត្រូវបានបង្ហាញដោយរង្វង់ពណ៌ខុសៗគ្នា ទៅតាមប្រភេទផ្សេងៗគ្នា។ ឧបករណ៍តាមដានការរំខានគម្របព្រៃឈើ (FCDM-រ៉ាដា) ដែលរកឃើញនៅឆ្នាំ២០២១ ត្រូវបានបង្ហាញជាមួយនឹងស្នាមពណ៌ក្រហមខណៈដែលការផ្លាស់ប្ដូរព្រៃឈើសកល (GFC) ឆ្នាំ២០២១ ត្រូវបានបង្ហាញជាមួយស្នាមពណ៌ខៀវ។ ពណ៌ស្វាយដែលត្រួតលើគ្នា គឺជាកន្លែងដែលសំណុំទិន្នន័យទាំងពីរស្របគ្នា។ សម្បទានដីសេដ្ឋកិច្ច (ELCs) ត្រូវបានបង្ហាញដោយពណ៌លឿងទុំ។

ដែនជម្រកសត្វព្រៃព្រះរកា មានទីតាំងស្ថិតនៅភាគខាងជើងប្រទេសកម្ពុជា ជិតព្រំដែនប្រទេសថៃ និងមានគម្របព្រៃឈើចំនួនជាង ៩០,៣៦១ ហិកតា។ មានជនជាតិដើមភាគតិចកួយ និងប្រជាជនធម្មតា ចំនួនជាង ១៥,០០០នាក់ រស់នៅក្នុងភូមិ ចំនួន ២២ភូមិ នៅជុំវិញព្រៃព្រះរកា។ ព្រៃព្រះរកាត្រូវបានកំណត់ជា ដែនជម្រកសត្វព្រៃ នៅឆ្នាំ ២០១៦។ វាត្រូវបានហ៊ុំព័ទ្ធដោយ ដីសម្បទានសេដ្ឋកិច្ច (ELCs) និងដែនជម្រក ត្រូវបានគំរាមកំហែងដោយ សម្បទានិក ដែលធ្វើសកម្មភាពកាប់ឈើ ដោយខុសច្បាប់។ ក្នុងរយៈពេលច្រើនជាងពីរទសវត្សរ៍ សមាជិករបស់ បណ្ដាញសហគមន៍ព្រៃព្រះរកា (PFCN) បាននឹងកំពុងធ្វើការយ៉ាងសកម្មដើម្បី ការពារព្រៃឈើ តាមរយៈការល្បាតដែលកត់ ត្រាការបាត់បង់ព្រៃឈើ ជីវចម្រុះ និងការប្រែប្រួល អាកាសធាតុ។ អ្នកល្បាតធ្វើការស្ទាក់ចាប់ និងចាប់រាល់ សកម្មភាពកាប់ឈើខុសច្បាប់ ជាប្រចាំ ផងដែរ។

## ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា)[36]

ដែនជម្រកសត្វព្រៃ ព្រះរកា




នៅឆ្នាំ២០២១ ដែនជម្រកសត្វព្រៃ ព្រះរកា បានបាត់បង់គម្របព្រៃឈើចំនួន ៨៦៨ ហិកតា ជាការបាត់បង់ខ្ពស់បំផុតក្នុងកំណត់ត្រា។ នេះគឺជាតំបន់មួយដែលទាក់ទងទៅនឹងការកើនឡើងចំនួន ៤៣% តាំពីឆ្នាំ ២០២០ និង ១.១% នៃការបាត់បង់គម្របព្រៃឈើសរុប។ តាំងពីឆ្នាំ២០០១មក ព្រៃឈើត្រូវបានបាត់បង់ចំនួន ៤,៤១០ ហិកតា ឬស្មើនឹង ៥.៧% នៃគម្របព្រៃឈើសរុប។[35]

2 កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ។ ២០១២។ ព្រៃសង្ឃសហគមន៍រុក្ខាវ័នកម្ពុជា។ ករណីសិក្សាជាស៊េរីនូវគំនិតផ្តួចផ្តើមអេក្វាទ័រ។ ញ៉ូយក (NY)៖ https://www.equatorinitiative.org/wp-content/uploads/2017/05/case_1348163303.pdf

3 សម្រាប់ដែនជម្រកសត្វព្រៃ សង្ឃសហគមន៍រុក្ខាវ័ន តួលេខត្រូវបានគណនាដោយប្រើប្រាស់ ព័ត៌មានលក្ខណៈភូមិសាស្ត្រ ដែលមិនរាប់បញ្ចូលតំបន់ពង្រីកនៅជុំវិញអូរផាល។ វាអនុញ្ញាតឱ្យយើងដកចេញនូវកំហុសឆ្គងដែល អាចកើតមានពីក្បួនដោះស្រាយក្នុងការគណនាការបាត់បង់ព្រៃឈើដោយស្វ័យប្រវត្តិ ដែលធ្វើឱ្យមានការយល់ខុសពីទំហំផ្ទៃទឹក។ ការប៉ាន់ប្រមាណសម្រាប់ ព្រៃសង្ឃសហគមន៍រុក្ខាវ័ន គឺលក្ខណៈអភិរក្ស។

# III. ដែនជម្រកសត្វព្រៃសង្ឃសហគមន៍រុក្ខាវ័ន




**រូបភាពទី៦**

ដែនជម្រកសត្វព្រៃ សង្ឃសហគមន៍រុក្ខាវ័ន (មានការប្រែប្រួលតិចតួច)[3]។ ព័ត៌មានភូមិសាស្ត្រ នៅខែធ្នូ ឆ្នាំ២០២១ ទិន្នន័យរូបភាព ត្រូវបានទាញយកពី មន្ទីពិសោធន៍ភព (Planet Labs)។ ទិន្នន័យឃ្លាំមើលព្រៃឈើ ត្រូវបានបង្ហាញដោយរង្វង់ពណ៌ខុសៗគ្នា ទៅតាមប្រភេទផ្សេងៗគ្នា។ ឧបករណ៍តាមដានការរំខានគម្របព្រៃឈើ (FCDM-រ៉ាដា) ដែលរកឃើញនៅឆ្នាំ២០២១ ត្រូវបានបង្ហាញជាមួយនឹងស្នាមពណ៌ក្រហម ខណៈពេលដែលការផ្លាស់ប្តូរព្រៃឈើសកល (GFC) ឆ្នាំ២០២១ ត្រូវបានបង្ហាញជាមួយស្នាមពណ៌ខៀវ។ ពណ៌ស្វាយដែលត្រួតលើគ្នា គឺជាកន្លែងដែលសំណុំទិន្នន័យទាំងពីរស្របគ្នា។ សម្បទានដីសេដ្ឋកិច្ច (ELCs) ត្រូវបានបង្ហាញដោយ ពណ៌លឿងទុំ។

ដែនជម្រកសត្វព្រៃសង្ឃសហគមន៍រុក្ខាវ័ន មានទំហំចំនួន ៣០,២៥៤ហិកតា ដែលជាព្រៃបៃតងគ្រប់រដូវកាល ដែលស្ថិតនៅភាគពាយព្យកម្ពុជា។ ការការពារព្រៃនេះ ត្រូវបានផ្តួចផ្តើមឡើងដោយ ព្រះសង្ឃព្រះនាម ព្រះតេជគុណ ប៊ុន សាលួត ដែលបានឃើញនូវការកាប់បំផ្លាញព្រៃឈើដ៏មានតម្លៃជាបន្តបន្ទាប់របស់កម្ពុជា។ អ្នកស្ម័គ្រចិត្ត និងអ្នកចុះល្បាត របស់ព្រៃសង្ឃសហគមន៍រុក្ខាវ័ន (MCF) បានចាប់ផ្តើមដើរល្បាតក្នុងព្រៃដើម្បីឃ្លាំមើល និងបញ្ឈប់សកម្មភាពប្រមូលផលឈើដោយខុសច្បាប់។ ក្នុងនាមជាព្រះសង្ឃ នៅក្នុងប្រទេសដែលគោរពព្រះពុទ្ធសាសនា បានអនុញ្ញាតឱ្យ សហគមន៍រក្សាបាននូវទំនាក់ទំនងល្អ ជាមួយអាជ្ញាធរមូលដ្ឋាន និងខេត្ត។ កិច្ចខិតខំប្រឹងប្រែង របស់ព្រះសង្ឃក្នុងកិច្ចការពារបរិស្ថាន និងការកាត់បន្ថយបទល្មើសព្រៃឈើ បានផ្តល់ផលប្រយោជន៍ដោយផ្ទាល់ដល់ប្រជាពលរដ្ឋចំនួនជាង ៣,៧០០នាក់ ដែលពឹងផ្អែកលើព្រៃឈើសម្រាប់របរចិញ្ចឹមជីវិត។[2]

## ការបាត់បង់គម្របព្រៃឈើប្រចាំឆ្នាំ (ហិកតា)[35]

ដែនជម្រកសត្វព្រៃ
សង្ឃសហគមន៍រុក្ខាវ័ន

នៅឆ្នាំ២០២១ ការបាត់បង់ព្រៃឈើមានការថយចុះ នៅក្នុងដែនជម្រកសត្វព្រៃសង្ឃសហគមន៍រុក្ខាវ័ន[3]។ មានការបាត់បង់គម្របព្រៃឈើចំនួន ២១ហិកតា ដែលជាទំហំមួយ មានការថយចុះចំនួន ៤៧% ចាប់តាំងពីឆ្នាំ២០២០ និងស្មើនឹង ០.២៣% នៃការបាត់បង់គម្របព្រៃឈើសរុប។ ចាប់តាំងពីឆ្នាំ២០០១ មានព្រៃឈើចំនួន ៤៨៦ហិកតា ត្រូវបានបាត់បង់ ឬស្មើនឹង ៥.៤% នៃគម្របព្រៃឈើសរុប។[37]



# ០៣ វិធីសាស្ត្រ[4]




សេចក្តីផ្តើម
ដែនជម្រកសត្វព្រៃ និងសហគមន៍
វិធីសាស្ត្រ
បញ្ហាប្រឈម ឆ្នាំ២០២១
លទ្ធផល
ចំនុចសំខាន់ៗ និងសេចក្តីសង្ខេប
សេចក្តីសន្និដ្ឋាន

CEEJA ប្រើប្រាស់ការឃ្លាំមើលនៅកម្រិតមូលដ្ឋានដោយសហគមន៍ ដែលរួមបញ្ចូលជាមួយនឹងការឃ្លាំមើលពីចម្ងាយ៖

I. ការឃ្លាំមើលនៅកម្រិតមូលដ្ឋាន និងសហគមន៍ដែលប្រមូលទិន្នន័យតាមរយៈ ការប្រើប្រាស់ កម្មវិធីទូរស័ព្ទស្មាតហ្វូន និងការប្រើប្រាស់ឧបករណ៍ដ្រូន។

II. វិធីសាស្ត្រឃ្លាំមើល ដោយប្រព័ន្ធបច្ចេកវិទ្យា ផ្កាយរណបទំនើប៖ ប្រព័ន្ធផ្តល់សញ្ញា GLAD (សាកលវិទ្យាល័យ Maryland) ឧបករណ៍ FCDM (មជ្ឈមណ្ឌលស្រាវជ្រាវរួមនៃគណៈកម្មាការអឺរ៉ុប) និងការវិភាគលើបណ្តុំរូបភាពតាមពេលវេលាដែលមានគុណភាពកម្រិតខ្ពស់ នៃតំបន់ត្រូពិចរបស់ពិភពលោក (Planet Labs-Norway International Climate and Forests Initiative)។




ប្រភពទិន្នន័យចំនួនពីរត្រូវបានបញ្ចូលគ្នា និងមើលឃើញនៅក្នុងប្រព័ន្ធសង្កេតព្រៃឈើរួមបញ្ចូលគ្នា (IFOROS)៖ វេទិកាអនឡាញដែលអាចត្រូវបានប្រើជាឧបករណ៍អន្តរកម្មមួយ ដើម្បីមើលឃើញពីប្រភេទព័ត៌មានផ្សេងៗគ្នា សម្រាប់តំបន់ការពាររបស់កម្ពុជា។ វាបានរួមបញ្ចូលគ្នាជាមួយបរិបទទិន្នន័យ ដូចជា តំបន់ការពារ ការជីកយករ៉ែ សម្បទានដីសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ផ្សេងៗទៀត។ ដែលវាផ្តល់ឱ្យអ្នកប្រើប្រាស់ នូវការធ្វើបច្ចុប្បន្នភាព និងទិដ្ឋភាពរួម នៃស្ថានភាពតំបន់ការពារ។ វេទិកានេះ អាចចូលប្រើប្រាស់បានតាមរយៈ https://iforos.live/platform ហើយវាត្រូវបានធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ជាមួយនឹងសំណុំទិន្នន័យចុងក្រោយបំផុត ស្តីពីការបាត់បង់គម្របដើមឈើ។ ទិន្នន័យដែលបង្ហាញនៅក្នុងរបាយការណ៍នេះ អាចត្រូវបានស្វែងរកយ៉ាងលម្អិតតាមរយៈតំណភ្ជាប់ខាងលើនេះ។



### វេទិកាមួយនេះអាចត្រូវបានប្រើប្រាស់ដោយ៖

- **អាជ្ញាធរ**
  ត្រួតពិនិត្យមើលព្រៃឈើ និងការអនុវត្តច្បាប់។
- **អ្នកសារព័ត៌មាន**
  ដែលចង់ធ្វើសេចក្តីរាយការណ៍ អំពីស្ថានភាពរបស់តំបន់ការពារ។
- **ស្ថាប័នសិក្សា**
  សម្រាប់សកម្មភាពដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវ។
- **អង្គការសង្គមស៊ីវិល ក្រុមតស៊ូមតិ និងសាធារណៈជនទូទៅ**
  ដើម្បីតស៊ូមតិ និងធ្វើឱ្យភាគីពាក់ព័ន្ធចូលរួមទទួលខុសត្រូវ។

4 ព័ត៌មានបន្ថែមទាក់ទងនឹងវិធីសាស្រ្តរបស់យើង អាចស្វែងរកបាននៅក្នុងរបាយការណ៍ឃ្លាំមើលលើកទី១៖ https://static-curis.ku.dk/portal/files/290599758/CEEJA_REPORT_FINAL_ONLINE_JAN22.pdf

# ០៤ បញ្ហាប្រឈម ឆ្នាំ២០២១


សេចក្តីផ្តើម

ដែនជម្រកសត្វព្រៃ និងសហគមន៍

វិធីសាស្ត្រ

បញ្ហាប្រឈម ឆ្នាំ២០២១

លទ្ធផល

ចំនុចសំខាន់ៗ និងសេចក្តីសង្ខេប

សេចក្តីសន្និដ្ឋាន


## ការឃុំខ្លួនសកម្មជន[5, 6, 7]




រូបភាពទី៨
សកម្មជនដែលត្រូវបានចាប់ខ្លួន ឈរនៅខាងក្រៅតុលាការខេត្តក្រចេះ ក្នុងខែកុម្ភៈ ឆ្នាំ២០២១។

ករណីយាយីដោយផ្លូវច្បាប់ ការគាបសង្កត់ និងការឃុំខ្លួនសកម្មជនបានកើនឡើងជាញឹកញាប់ ក្នុងអំឡុងពេលការរាតត្បាតដោយជំងឺ កូវីដ-១៩។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ អ្នកការពារបរិស្ថានដែលឈ្នះពានរង្វាន់លោក អ៊ូច ឡេង និងសមាជិកក្រុមរបស់គាត់ ចំនួនបួននាក់ទៀតត្រូវបានចាប់ខ្លួន ដោយសារការដាក់ស្លាកសញ្ញា "ហាមកាប់ឈើ" និងការយកស្បង់ជីវ ទៅរុំនឹងដើមឈើ។ ក្នុងខែតុលា ឆ្នាំដដែល សកម្មជនបរិស្ថាន លោក ចាន់ ធឿន បានទទួលការព្យួរទោសរយៈពេលពីរឆ្នាំ ពីបទរំលោភលើអ្នកកាប់ឈើ។ តាមពិតលោក ធឿន កំពុងចងក្រងឯកសារស្តីពីការដឹកជញ្ជូនឈើដោយខុសច្បាប់។ ការចាប់ខ្លួន និងការកាត់ទោសទាំងនេះ បង្ហាញពីឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការបំបិទមាត់ និងរារាំងរាល់ការតស៊ូមតិណាមួយដែលប្រឈមនឹងការគាំទ្ររបស់ពួកគេ ចំពោះការកេងប្រវ័ញ្ចធនធានធម្មជាតិរបស់កម្ពុជា ដោយឥតឈប់ឈរ ដូចអ្វីដែលបានលើកឡើង នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់អង្គការលើកលែងទោសអន្តរជាតិផងដែរ។[8]



**រូបភាពទី៩**
**ព្រះសង្ឃកំពុងរៀបចំកម្មវិធីបុណ្យបំបួសដើមឈើ នៅក្នុងដែនជម្រកសត្វព្រៃ សង្ឃសហគមន៍រុក្ខាវ័ន។**

## ភាពតានតឹង និងការបង្វែរ មូលនិធិរបស់ USAID[12.13.14]

នៅក្នុងរបាយការណ៍ឃ្លាំមើលមុន បណ្តាញសហគមន៍ព្រៃឡង់ (PLCN) បានរិះគន់គម្រោងព្រៃឡង់បៃតង (GPL) របស់ USAID ដែលធ្វើតាមរដ្ឋាភិបាលសម្រាប់ការអើពើរចំពោះ សកម្មភាពបន្តកាប់បំផ្លាញព្រៃឈើ និងការគាំទ្រដោយប្រយោល លើកម្មវិធីដើរល្បាតដែលគ្រប់គ្រង់ដោយរដ្ឋាភិបាល ដែលមិនរាប់បញ្ចូលប្រជាជនមូលដ្ឋាន និងជនជាតិដើមភាគតិចដែលនៅជាមួយដែនជម្រកសត្វព្រៃ និងធ្វើសកម្មភាពតិចតួចក្នុងការទប់ស្កាត់ការកាប់ឈើខុសច្បាប់។ នៅឆ្នាំ២០២១ គម្រោង GPL របស់ USAID បានប្រកាសពីការ បញ្ចប់ជំនួយរបស់ខ្លួន ដល់ស្ថានប័នរដ្ឋាភិបាល និងបង្វែរមូលនិធិទាំងនោះទៅកាន់សហគមន៍មូលដ្ឋាន ដែលមានកិច្ចខិតខំប្រឹងប្រែង ក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅ។ ទោះជាយ៉ាងណាក៏ដោយ វាបានបរាជ័យក្នុងការអញ្ជើញបណ្តាញផ្លូវការនៃសហគមន៍មូលដ្ឋាន PLCN ដើម្បីធ្វើការពិគ្រោះយោបល់។ អ្នកគ្រប់គ្រង់គម្រោង GPL របស់ USAID បានបន្តធ្វើបន្ថែមទៀត និងបានចេញសេចក្តីថ្លែងការណ៍មិនពិតមួយ ដែលលើកកម្ពស់កិច្ចសហការរវាង GPL និងបណ្តាញព្រៃឈើ។ នៅក្នុងសេចក្តីប្រកាសមួយដែលបានធ្វើឡើងក្នុងខែមីនា ឆ្នាំ២០២១ PLCN បានថ្កោលទោសចំពោះការប្រើប្រាស់ឈ្មោះរបស់ PLCN ដោយ USAID និងបានបញ្ជាក់ថា បណ្តាញសហគមន៍ព្រៃឡង់មិនដែលត្រូវបានរាប់បញ្ចូលជា ភាគីពាក់ព័ន្ធនៅក្នុងគម្រោង GPL នោះទេ។

## ការថ្លែងខុសពីការពិត ការបង្ខំឱ្យចុះកិច្ចសន្យា និងការហាមឃាត់[9, 10, 11]

មានទម្រង់លាក់កំបាំង ជាច្រើនផ្សេងទៀត នៃការជម្រុញរបស់រដ្ឋាភិបាលប្រឆាំង នឹងចលនាបរិស្ថានដែលប្រយុទ្ធដើម្បីសង្គ្រោះ ដែនជម្រកសត្វព្រៃរបស់កម្ពុជា។ កាលពីខែកុម្ភៈ ក្រសួងបរិស្ថានបានហាមឃាត់ការប្រារព្ធពិធីបុណ្យព្រៃឡង់ និងបំបួសដើមឈើប្រចាំឆ្នាំ ក្រោមលេសថា មិនគួរប្រារព្ធពិធីនេះនៅក្នុងតំបន់ការពារ។ នៅក្នុងសេចក្តីថ្លែងការណ៍ស្រដៀងគ្នានេះដែរ ក្រសួងបានបញ្ជាក់ថា ការកាប់ឈើខុសច្បាប់ គឺបានកើតឡើងនៅក្នុងកម្រិតតូចតាច ដោយប្រជាជនដែលរស់នៅមូលដ្ឋាន និងមិនមែនជាសកម្មភាពរបស់ក្រុមហ៊ុនធំៗ (ឆ្លងប្រទេស) ដែលប្រតិបត្តិការនៅជុំវិញតំបន់ដែនជម្រកសត្វព្រៃ ដូចការលើកឡើងនៅក្នុងរបាយការណ៍មួយរបស់ ពីគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មចំឆ្លងដែននោះទេ។[15] រដ្ឋាភិបាលក៏បានព្យាយាមបង្ខំអ្នកដើរល្បាត ឱ្យចុះកិច្ចសន្យាដែលហាមឃាត់ពួកគេមិនឱ្យចូលព្រៃ ដោយគ្រាន់តែបញ្ជាក់ថា ជាបទបញ្ជាដោយសារ PLCN មិនបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការ។ សរុបមក ការរុញច្រានរបស់រដ្ឋាភិបាលទាំងនេះ គឺជាការរំលោភបំពានសិទ្ធិមនុស្សយ៉ាងពិតប្រាកដ ដូចដែលតំណាង បណ្តាញសហគមន៍ព្រៃឡង់ លោក ខេម សុឃី បានអះអាង។[9]

5 https://newint.org/features/2021/02/15/forest-defenders-under-fire-cambodia

6 https://vodenglish.news/award-winning-environmentalist-four-others-arrested-in-kratie/

7 https://vodenglish.news/prey-lang-activist-handed-two-year-suspended-sentence/

8 ព្រៃឡង់របស់កម្ពុជា៖ តើអាចមិនការពារ ព្រៃដ៏សំខាន់មួយនេះ ដោយរបៀបណា? https://www.amnesty.org/en/latest/news/2021/04/cambodias-prey-lang-how-not-to-protect-a-vital-forest/

9 https://cambodianess.com/article/environment-ministry-prohibits-local-community-from-holding-prey-lang-ordination-ceremony

10 https://www.phnompenhpost.com/national/govt-rejects-logging-claims

11 https://vodenglish.news/prey-lang-community-patrollers-asked-to-sign-contracts-to-formalize-bans/

12 https://cambojanews.com/prey-lang-patrollers-criticize-us-claim-it-supported-the-forest-group/

13 https://cambodianess.com/article/failing-conservation-efforts-in-prey-lang-once-again-focus-of-scrutiny

14 សេចក្តីថ្លែងការណ៍របស់ ស្ថានទូតសហរដ្ឋអាមេរិកប្រចាំទីក្រុងភ្នំពេញ ស្តីពីការបង្វែរមូលនិធិព្រៃឡង់បៃតងរបស់ USAID៖ https://kh.usembassy.gov/u-s-embassy-phnom-penh-statement-on-the-usaid-greening-prey-lang-funding-redirect/

សេចក្តីផ្តើម

ដែនជម្រកសត្វព្រៃ
និងសហគមន៍

វិធីសាស្រ្ត

បញ្ហាប្រឈម
ឆ្នាំ២០២១

លទ្ធផល

ចំនុចសំខាន់ៗ
និងសេចក្តីសង្ខេប

សេចក្តីសន្និដ្ឋាន


# ឧក្រិដ្ឋកម្មឆ្លងដែន និងអំពើពុករលួយ[15]

នៅឆ្នាំ២០២១ គំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន បានចេញផ្សាយរបាយការណ៍លម្អិតមួយ ដែលបង្ហាញពីខ្សែសង្វាក់ផ្គត់ផ្គង់ដ៏ស្មុគស្មាញ និងបរិយាកាសនីតិបញ្ញត្តិដ៏ពុករលួយ ដែលបានជំរុញឱ្យមានការកាប់ឈើខុសច្បាប់ នៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ ផ្តល់ភាពស្របច្បាប់ និងភស្តុតាងបន្ថែមទៀត ចំពោះការអះអាងដែល PLCN បាននិងកំពុងធ្វើការនៅក្នុងរយៈពេល ប៉ុន្មានឆ្នាំកន្លងមកនេះ ដោយបង្ហាញពីរបៀបដែល ក្រុមហ៊ុនដូចជាក្រុមហ៊ុន Macle Logistics Cambodia Co Ltd និងក្រុមហ៊ុន PNT Co Ltd ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មព្រៃឈើ និងអំពើពុករលួយនៅក្នុងក្រសួងបរិស្ថាន ដែលកំពុងជំរុញឱ្យមានការកាប់បំផ្លាញព្រៃឈើ។

# ការលាក់បាំងពីក្រោយ ថាមពលបៃតង និងខ្សែថាមពលអគ្គីសនី[16, 17, 18]

កម្ពុជាបានបដិសេធមិនចុះហត្ថលេខា លើកិច្ចសន្យាអភិរក្ស និងជួយបង្កើតព្រៃឈើឡើងវិញក្នុងកិច្ចពិភាក្សាស្តីពីអាកាសធាតុសកល របស់អង្គការសហប្រជាជាតិ នៅខែវិច្ឆិកា ឆ្នាំ២០២១។ ក្រសួងបរិស្ថានបានប្រកាសអំពីការសម្រេចនេះ ប៉ុន្តែមិនបានផ្តល់ការពន្យល់នោះទេ។ ផ្ទុយទៅវិញ អ្នកនាំពាក្យក្រសួងបរិស្ថាន បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការសម្រួលដល់ការអភិវឌ្ឍន៍ថាមពលបៃតង ដោយការចុះហត្ថលេខាលើ គំនិតផ្តួចផ្តើមក្រឡាចក្រត្រង់បៃតង (GGI)។ ប៉ុន្តែកាលពីឆ្នាំមុន រដ្ឋាភិបាលកម្ពុជាបានប្រកាសគម្រោងសាងសង់បង្គោលខ្សែបញ្ជូនអគ្គីសនីប្រវែង ២៩៩គីឡូម៉ែត្រ ដែលនឹងកាត់តាមតំបន់ដែនជម្រកសត្វព្រៃព្រៃឡង់ និងតំបន់គម្រោងរ៉េដបូកមួយ។ ខ្សែថាមពលអគ្គីសនី នឹងជះឥទ្ធិពលអវិជ្ជមានយ៉ាងខ្លាំងទៅលើជីវៈចម្រុះរបស់ដែនជម្រកសត្វព្រៃ។ ឯកសារលេចធ្លាយបង្ហាញថា ការពិគ្រោះយោបល់រឹងមាំមួយលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន បានបង្ហាញ រដ្ឋាភិបាលនូវជម្រើសជំនួសចំនួនពីរ និងមានតម្លៃទាបជាងខ្សែថាមពលអគ្គីសនីដែលត្រូវឆ្លងកាត់ព្រៃឡង់។ ការជ្រើសរើសរបស់រដ្ឋាភិបាលក្នុងការស្វែងរកដំណោះស្រាយ ដែលបំផ្លិចបំផ្លាញបំផុត និងថ្លៃបំផុត ធ្វើឱ្យមានការព្រួយបារម្ភថា ជាការសម្រេចចិត្តដែលមានលក្ខណៈនយោបាយ និងជាប់ពាក់ព័ន្ធនឹងអំពើពុករលួយ។




**រូបភាពទី១០**
ដែនជម្រកសត្វព្រៃ ព្រៃឡង់ ជាព្រៃដែលមានទេសភាពព្រៃឈើចុងក្រោយ (IFL) របស់កម្ពុជា ដែលជាព្រៃដែលដុះឡើងនៅក្នុងតំបន់ព្រៃចាស់ដែលមានទំហំធំល្មម និងគ្មានការរំខានដល់ការរក្សាកម្រិតជីវចម្រុះដើមរបស់វា។ ខណៈពេលដែលផ្លូវដែលបានគ្រោងទុកសម្រាប់បង្គោលខ្សែថាមពលអគ្គីសនី នឹងកាត់ផ្តាច់តំបន់ព្រៃជាពីរផ្សេងគ្នា នៃតំបន់ទេសភាពព្រៃឈើមួយនេះ។ នៅផ្នែកភាគខាងជើងបានបង្ហាញពីការចែកព្រៃជាពីរដែលមើលឃើញនៅត្រឹមឆ្នាំ២០២០។
ប្រភព Mongabay[17]

[15] https://globalinitiative.net/analysis/forest-crimes-cambodia/

[16] https://vodenglish.news/cambodia-cops-out-of-forest-protection-pledge-at-cop26/

[17] https://vodenglish.news/power-line-to-cut-through-prey-lang-troubling-conservation-partners/

[18] https://news.mongabay.com/2022/06/opaque-infrastructure-plans-a-death-sentence-for-cambodias-prey-lang-wildlife-sanctuary/

[19] https://redd-monitor.org/2021/09/06/new-report-reveals-large-scale-deforestation-in-tumring-redd-project-in-cambodia/

[20] https://vietnamagriculture.nongnghiep.vn/legal-proof-needed-for-timber-imported-from-cambodia-d291336.html

# ដែនកំណត់ របស់រ៉េដបូក[19]

គម្រោងរ៉េដបូកទំរីង (Tumring REDD+) គ្របដណ្តប់លើផ្ទៃដីជាង ៦៧,០០០ហិចតា នៅក្បែរនឹងដែនជម្រកសត្វព្រៃព្រៃឡង់ ហើយត្រូវបានប្រកាសជាយូរមកហើយថា ជាកិច្ចសហប្រតិបត្តិការដ៏ជោគជ័យរវាងរដ្ឋាភិបាលកម្ពុជា និងកូរ៉េខាងត្បូង។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងរបាយការណ៍ថ្មីៗនេះដែលប្រើប្រាស់ការប្រមូលទិន្នន័យនៅនឹងកន្លែង ការវិភាគរូបភាពដោយផ្កាយរណប និងការសម្ភាសន៍ បានរកឃើញការកាប់បំផ្លាញព្រៃឈើទ្រង់ទ្រាយធំ នៅក្នុងតំបន់របស់គម្រោងរ៉េដបូកមួយនេះ។ របាយការណ៍បញ្ជាក់ថា ជាង ៣៧% នៃតំបន់ព្រៃរេដបូក ត្រូវបានកាប់បំផ្លាញដោយផ្នែក ឬទាំងស្រុង។ ដីព្រៃទំហំជិត ៥,០០០ហិកតា ត្រូវបានបាត់បង់នៅខាងក្នុងតំបន់របស់គម្រោង ក្នុងឆ្នាំ២០២១ ដែលបង្ហាញថា សេចក្តីថ្លែងការណ៍របស់សេវាកម្មព្រៃឈើកូរ៉េ ដែលអះអាងថា "មិនមានការកាប់ឈើខុសច្បាប់ទ្រង់ទ្រាយធំនៅក្នុងទីតាំងគម្រោងរបស់ខ្លួននៅកម្ពុជានោះទេ" គឺមិនត្រឹមត្រូវឡើយ។




**រូបភាពទី១១**
គម្រោងរ៉េដបូកទំរីង។ ព័ត៌មានភូមិសាស្ត្រនៅក្នុងខែធ្នូ ឆ្នាំ២០២១ ទិន្នន័យរូបភាពត្រូវបានទាញយកពីមន្ទីរពិសោធន៍ភព (Planet Labs)។ ឧបករណ៍តាមដានការរំខានគម្របព្រៃឈើ (FCDM-រ៉ាដា) រកឃើញនៅឆ្នាំ២០២១ ដែលត្រូវបានបង្ហាញដោយស្នាមពណ៌ក្រហម ខណៈសំណុំទិន្នន័យការផ្លាស់ប្តូរព្រៃឈើសកល (GFC) ឆ្នាំ២០២១ ត្រូវបានបង្ហាញដោយស្នាមពណ៌ខៀវ។ ពណ៌ស្វាយដែលត្រួតលើគ្នា គឺជាកន្លែងដែលសំណុំទិន្នន័យទាំងពីរស្របគ្នា។




# សមាគមឈើរបស់វៀតណាមប្រយុទ្ធប្រឆាំងការនាំចូលឈើខុសច្បាប់[20]

សមាគមឈើរបស់វៀតណាម បានទាក់ទងទៅកាន់ រដ្ឋាភិបាលកម្ពុជា ដើម្បីសុំការបំភ្លឺទាក់ទងនឹងឯកសារវាយតម្លៃ ភាពស្របច្បាប់នៃការនាំចូលឈើ។ ការអំពាវនាវនេះ បានធ្វើឡើងបន្ទាប់ពីមានការកើនឡើងនូវឈើខុសច្បាប់របស់កម្ពុជា ឆ្លងកាត់ព្រំដែនវៀតណាម បើទោះបីជាមានការហាមឃាត់ពីរដ្ឋាភិបាលកម្ពុជាក៏ដោយ។

# ០៥ លទ្ធផល

សេចក្តីផ្តើម
ដែនជម្រកសត្វព្រៃ និងសហគមន៍
វិធីសាស្ត្រ
បញ្ហាប្រឈមឆ្នាំ២០២១
លទ្ធផល
ចំនុចសំខាន់ៗ និងសេចក្តីសង្ខេប
សេចក្តីសន្និដ្ឋាន









ការបែងចែកទិន្នន័យ

# ប្រភេទទិន្នន័យសំខាន់ៗ

មកពីសហគន៍ចំនួនបីផ្សេងគ្នា

**រូបភាពទី១២**
ការបែងចែកទិន្នន័យ ដែលមានសុពលភាព
ដែលបានកត់ត្រាដោយសហគមន៍ចំនួនបីផ្សេងគ្នា
សម្រាប់ប្រភេទទិន្នន័យសំខាន់ៗ សម្រាប់ឆ្នាំ២០២១។

MCF PFCN PLCN

ការបែងចែកទិន្នន័យនៅក្នុង

# ការកាប់ឈើខុសច្បាប់

ប្រភេទទិន្នន័យ មកពីសហគមន៍ចំនួនបីផ្សេងគ្នា

**រូបភាពទី១៣**
ការបែងចែកទិន្នន័យ ដែលមានសុពលភាព ដែលបានកត់ត្រា
ដោយសហគមន៍ចំនួនបីផ្សេងគ្នា សម្រាប់ប្រភេទទិន្នន័យ
"ការកាប់ឈើខុសច្បាប់" សម្រាប់ឆ្នាំ២០២១។

MCF PFCN PLCN

ការបែងចែកទិន្នន័យនៅក្នុង

# ធនធាន

ប្រភេទទិន្នន័យ មកពីសហគមន៍ចំនួនបីផ្សេងគ្នា

**រូបភាពទី១៣**
ការបែងចែកទិន្នន័យ ដែលមានសុពលភាព ដែលបានកត់ត្រា
ដោយសហគមន៍ចំនួនបីផ្សេងគ្នា សម្រាប់ប្រភេទទិន្នន័យ
"ធនធាន" សម្រាប់ឆ្នាំ២០២១។

MCF PFCN PLCN

## I. បណ្តាញសហគមន៍ព្រៃឡង់ (PLCN)

**១,៥៧៨**
**ទិន្នន័យ**

បើទោះជាមាន បរិយាកាសប្រឈមឥតឈប់ឈរក៏ដោយ សមាជិកបណ្តាញសហគមន៍ព្រៃឡង់ បានប្រមូលទិន្នន័យយ៉ាងច្រើន ធៀបនឹងឆ្នាំ២០២០។ នៅក្នុងឆ្នាំ២០២០ រាជរដ្ឋាភិបាលបានហាមឃាត់សកម្មភាពល្បាត និងការរឹតត្បិតក្រោមហេតុផលជំងឺកូវីដ បណ្តាលឱ្យការប្រមូលទិន្នន័យតិចជាងចំនួន ២៣០ទិន្នន័យ ខណៈឆ្នាំ២០២១ សម្គាល់ឃើញទិន្នន័យដែលមានសុពលភាពចំនួន ១,៥៧៨ទិន្នន័យ។ ស្ថិតិខាងក្រោមផ្តល់ការពន្យល់លម្អិតរបស់ទិន្នន័យទាំងអស់។ ទាំងនេះគឺជាលទ្ធផលដ៏សំខាន់សម្រាប់ឆ្នាំនេះ៖

- ច្រើនជាងពាក់កណ្តាលស្មើនឹង ៥៧% នៃទិន្នន័យទាំងអស់ គឺទាក់ទងទៅនឹងធនធាន ខណៈដែលភាគច្រើននៃទិន្នន័យដែលនៅសល់ គឺទាក់ទងទៅនឹងសកម្មភាពខុសច្បាប់ ស្មើនឹង ៣៧%។ ធាតុអាកាស សេចក្តីរាយការណ៍ និងទិន្នន័យផ្សេងៗទៀត មានប្រហែលត្រឹម ៦% នៃទិន្នន័យសរុប។

- សម្រាប់សកម្មភាព គឺមានចំនួន ៩៥% នៃទិន្នន័យទាំងអស់ គឺជាការកាប់ឈើខុសច្បាប់។

- អ្នកដើរល្បាតបានជួបប្រទះជាង ២៩៦កន្លែង ដែលជាដង្គត់ឈើដែលមានតម្លៃដែលគេបានកាត់រួច និងចំនួន ៦២កន្លែងទៀតជាដើមឈើដែលបានកាត់រំលំនឹងអារជ្រៀករួច។ ចំនួន ៨៨ទិន្នន័យ ដែលបានកត់ត្រាគឺជា "តំបន់ដែលបានកាប់រាន" នៅក្នុងផ្ទៃដីកាប់រានចាស់។ ទីបំផុតករណីដឹកជញ្ជូនឈើខុសច្បាប់ មានចំនួន ១១២ទិន្នន័យ។

- ទាក់ទងនឹងការរាយការណ៍អំពីធនធានដ៏មានតម្លៃ ដែលនៅបន្តមានវត្តមាន អ្នកដើរល្បាតបានកត់ត្រាដើមឈើចំនួន ៦៦៥ទិន្នន័យ ជាធនធាន ដែលភាគច្រើនស្មើនឹង ៨០% គឺជាដើមឈើប្រណីត និងចំនួន ២០% ជាដើមច្បោះ។

ការរកឃើញទាំងនេះ ឆ្លុះបញ្ចាំងពី ការសង្កេតរបស់សហគមន៍ដែលមើលឃើញថាពួកគេត្រូវបានហាមឃាត់មិនឱ្យចូលព្រៃ ខណៈអ្នកកាប់ឈើខុសច្បាប់ ត្រូវបានអនុញ្ញាតឱ្យចេញចូលដោយសេរី និងដឹកជញ្ជូនឈើដោយគោយន្ត និងការដឹកជញ្ជូនដោយមធ្យោបាយផ្សេងៗទៀត។ ការដឹកជញ្ជូនឈើបន្តទាំងថ្ងៃយប់ទាំង ដោយឆ្លងកាត់ស្នាក់ការត្រួតពិនិត្យរបស់មន្ត្រីឧទ្យានុរក្ស ដោយគ្រាន់តែបង់ប្រាក់ជាការស្រេច។ ឈើដែលត្រូវបានកាប់ដោយខុសច្បាប់ ភាគច្រើនជាប់ពាក់ព័ន្ធនឹងដីសម្បទាន ដែលលេចធ្លោជាងគេគឺ ក្រុមហ៊ុន Angkor Plywood Co., Ltd និងក្រុមហ៊ុន Think Biotech Co. Ltd នៅក្នុងខេត្តក្រចេះ ព្រមទាំងក្រុមហ៊ុន Thy Nga Co. Ltd ក្រុមហ៊ុន PNT និងក្រុមហ៊ុន Macle Logistics ក្នុងខេត្តព្រះវិហារ។

អន្ទាក់សត្វដែលត្រូវបានបង្កើតឡើង ដោយឧបករណ៍អេឡិចត្រូនិកប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវចម្រុះ និងសត្វព្រៃ។ ទន្ទឹមនឹងនោះ ក៏មានការកើន ឡើងនូវការប្រើប្រាស់កាំភ្លើងកែច្នៃ សម្រាប់បរបាញ់សត្វព្រៃ វាថែមទាំងគំរាម កំហែងដល់សមាជិកសហគមន៍ និងសកម្មជនបរិស្ថានផងដែរ។



**រូបភាពទី១៥**
គោយន្តមួយគ្រឿង កំពុងដឹកជញ្ជូនឈើទាំងយប់។ វាជាទម្លាប់ធម្មតាទៅហើយ និងអ្នកភូមិនិយាយថា ពួកគេពិបាកក្នុងការគេងលក់ដោយសារតែសំឡេងរំខានរបស់គោយន្ត។ ទិន្នន័យត្រូវបានរាយការណ៍ដោយសហគមន៍ នៅខេត្តព្រះវិហារ។

**២៥ កក្កដា**

ទីបំផុត សហគមន៍កំពុងជួបប្រទះ ការកាប់រានដីព្រៃ និងការសង់លំនៅឋានអនាធិបតេយ្យ នៅក្នុងតំបន់ការពារ និងក្នុងតំបន់ស្នូល នៃដែនជម្រកសត្វព្រៃ ព្រៃឡង់ ដែលជាប់ពាក់ព័ន្ធនឹងមន្ត្រីជាន់ខ្ពស់ និងជនចំណាកស្រុកមកពីតំបន់ផ្សេងៗ។[39]

ការដឹងជញ្ជូនឈើ មានការកើនឡើង

ការគំរាមកំហែង លើសមាជិកសហគមន៍

អន្ទាក់សត្វបង្កអន្តរាយដល់ជីវចម្រុះ និងសត្វព្រៃ

ការសងលំនៅឋាន អនាធិបតេយ្យ

**៥៥២**
**ទិន្នន័យ**

## II. បណ្តាញសហគមន៍ព្រៃព្រះរកា (PFCN)

សមាជិកបណ្តាញសហគមន៍ព្រៃព្រះរកា ក៏អាចបង្កើនការចុះល្បាតរបស់ខ្លួនបើធៀបនឹងឆ្នាំមុនៗ។ ជាមួយនឹងចំនួនសរុប ៥៥២ទិន្នន័យ ដែលទាំងនេះគឺ ជាលទ្ធផលឆ្នាំ២០២១៖

• ជាង ៧០% នៃទិន្នន័យទាំងអស់បានកត់ត្រាពីធនធាន ខណៈដែល ១៩% ទាក់ទង នឹងសកម្មភាព។ អ្នកដើរល្បាតក៏បានកត់ត្រាទិន្នន័យសំខាន់ៗ (៨%) ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងចំនួនតូចមួយនៃទិន្នន័យ គឺជាសេចក្តីរបាយការណ៍ និង ប្រភេទផ្សេងទៀត។

• ចំនួន ៩៧% នៃសកម្មភាពដែលបានកត់ត្រាទាំងអស់ គឺទាក់ទងនឹងសកម្មភាពនៃការកាប់ឈើខុសច្បាប់។

• ក្នុងនោះចំនួន ៥៣% នៃទិន្នន័យទាក់ទងទៅនឹងតំបន់ដែលបានកាប់រាន ចំនួន ២៥% ជាដង្គត់ឈើ ចំនួន ១៤% ជាបន្ទះឈើ និងចំនួន ៨% ជាករណីការដឹកជញ្ជូន។

• អ្នកល្បាតរបស់បណ្តាញសហគមន៍ព្រៃព្រះរកាបានកត់ត្រាចំនួន ៣៦៤ទិន្នន័យ ជាធនធាន ចំនួន ២៨៨ទិន្នន័យ (៧៩%) គឺជាដើមឈើ ដែលភាគច្រើននៃចំនួន (៨២%) ជាដើមឈើប្រណីត និងដើមច្បោះ (១៨%)។ ពួកគេក៏បានជួបប្រទះសត្វចំនួន (១០%) អនុផលព្រៃឈើមិនមែនឈើចំនួន (៩%) និងចំនួន (២%) ជាទីតាំងពិសិដ្ឋ។

ដូចគ្នានឹង សហគមន៍ព្រៃឡង់ដែរ បណ្តាញសហគមន៍ព្រៃព្រះរកា ក៏ត្រូវបានរឹតត្បិតមិនឱ្យចុះល្បាតព្រៃ ខណៈដែលអ្នកកាប់ឈើខុសច្បាប់បានបង្កើនសកម្មភាពរបស់ពួកគេ ដោយការដឹកជញ្ជូនឈើទាំងថ្ងៃទាំងយប់ ដោយគ្មានកិច្ចអន្តរាគមន៍ពីអាជ្ញាធរពាក់ព័ន្ធឡើយ។ ការឈូសឆាយដីព្រៃបានកើនឡើង រួមទាំងតំបន់ពិសិដ្ឋក្នុងដែនជម្រកសត្វព្រៃព្រះរកា ខណៈពេលដែលមានការកើនឡើងនូវភ្លើងឆេះព្រៃ។ នេះគឺជាការប៉ះពាល់ដល់ជីវភាពរបស់ សមាជិកសហគមន៍ដែលពឹងផ្អែកលើដើមច្បោះសម្រាប់ការរស់នៅរបស់ពួកគេ។

ទន្ទឹមនឹងនោះ សមាជិកសហគមន៍ដែលសកម្មក្នុងសកម្ម ក្នុងសកម្មភាពកិច្ចការការពារបរិស្ថាន កំពុងត្រូវបានស្ថិតក្រោមមុខសញ្ញារបស់តុលាការ ប៉ុន្តែក៏ត្រូវបានគំរាមកំហែងដោយអាវុធកែច្នៃរបស់ជនល្មើសផងដែរ។

ការកាប់ឈើ
មានការកើនឡើង

សហគមន៍ក្លាយជាមុខ
សញ្ញារបស់តុលាការ

ភ្លើងឆេះព្រៃ
មានការកើនឡើង

ចុងក្រោយនេះ ការជួញដូរសត្វព្រៃ នៅតែមានជាបន្តបន្ទាប់ និងគ្មានការរឹតបន្តឹង ទីតាំងលក់គ្រឿងសង្ហារិមធ្វើពីឈើប្រណីត ដែលកំពុងបើកកាន់តែច្រើន នៅជុំវិញដែនជម្រកសត្វព្រៃព្រះរកា។[39]

ការជួញដូរសត្វព្រៃនៅតែ
បន្តកើតមាន



**រូបភាពទី១៦**
តំបន់កាប់រានមួយកន្លែងត្រូវបានរាយការណ៍
នៅក្នុងដែនជម្រកសត្វព្រៃ ព្រះរកា។

១៨ ឧសភា

១២៦
ទិន្នន័យ

## III. ព្រៃសង្ឃសហគមន៍រុក្ខាវ័ន (MCF)

សមាជិកព្រៃសង្ឃសហគមន៍រុក្ខាវ័ន បានកត់ត្រាទិន្នន័យដែលមានសុពលភាពសរុបចំនួន ១២៦ទិន្នន័យ នៅឆ្នាំដំបូងដែលពួកគេប្រើប្រាស់កម្មវិធីលើទូរស័ព្ទដៃស្មាតហ្វូន៖

- នៅអំឡុងឆ្នាំ២០២១ អ្នកល្បាតព្រៃបានកត់ត្រាទិន្នន័យចំនួន ៥០ទិន្នន័យ ជាសកម្មភាព។ ចំនួន ៥៧ទិន្នន័យ ជាធនធានធម្មជាតិ។ ចំនួន ១១ទិន្នន័យ ជាអាកាសធាតុ និងចំនួន ៤ទិន្នន័យ ជាសេចក្តីរាយការណ៍និងផ្សេងៗ។

- ចំនួន ៧៨% នៃសកម្មភាពទាំងអស់ដែលទាក់ទងនឹងករណីនៃការកាប់ឈើខុសច្បាប់ ដែលអ្នកដើរល្បាតបានជួបប្រទះចំនួន ២៨ទីតាំង ជាមួយនឹងដង្កត់ឈើ (៧២%) និង ចំនួន ១១ទីតាំង (២៨%) ជាតំបន់ដែលត្រូវបានកាប់រានធំជាង។

- សមាជិកក៏បានប្រមូលទិន្នន័យអំពី ធនធានដ៏មានតម្លៃនៅក្នុងតំបន់ការពារផងដែរ៖ មានចំនួន ២៤ទិន្នន័យ ជាដើមឈើ ប្រណីត (៩៦%) និងដើមច្បោះ (៤%)។ ចំនួន ២៣ទិន្នន័យ ជាសត្វព្រៃ ចំនួន ៩ទិន្នន័យ ជាអនុផលព្រៃឈើ និងចំនួន ១ទិន្នន័យ ជាទីតាំងពិសិដ្ឋ។

សេចក្តីផ្តើម

ដែនជម្រកសត្វព្រៃ និងសហគមន៍

វិធីសាស្រ្ត

បញ្ហាប្រឈម ឆ្នាំ២០២១

**លទ្ធផល**

ចំនុចសំខាន់ៗ និងសេចក្តីសង្ខេប

សេចក្តីសន្និដ្ឋាន

ផ្អែកទៅលើ សមាជិកព្រៃសង្ឃសហគមន៍រុក្ខាវ័ន ដែលតែងតែរៀបចំ ការល្បាតរួមគ្នាជាទៀតទាត់ ជាមួយអាជ្ញាធរមូលដ្ឋាន បានលើកឡើងថា ឈើប្រណិត នៅតែបន្តកាប់ និងដឹកជញ្ជូនឥតឈប់ឈរ។

ការជួញដូរសត្វព្រៃ និងការនេសាទ ជាលក្ខណៈពាណិជ្ជកម្ម បានកើនឡើងដូចគ្នា ជាមួយនឹងភ្លើងឆេះព្រៃ ខណៈដែលការកាប់ឆ្ការព្រៃដើម្បីកាន់កាប់ដីធ្លីបានរារាំងដល់ការកំណត់ព្រំប្រទល់ និងកិច្ចការពារដែនជម្រកសត្វព្រៃ។[39]

**១៦ កញ្ញា**

ការកាប់ឈើ
មានការកើនឡើង

ភ្លើងឆេះព្រៃ
មានការកើនឡើង

ការជួញដូរសត្វព្រៃនៅ
តែបន្តកើតមាន

**រូបភាពទី ១៧**
ដង្គត់ឈើមួយដែលត្រូវបានរាយការណ៍ នៅក្នុងដែនជម្រកសត្វព្រៃ
សង្ឃសហគមន៍រុក្ខាវ័ន។



# ០៥ ចំនុចសំខាន់ៗ និងសេចក្ដីសង្ខេប

សំណុំទិន្នន័យត្រួតគ្នា បង្ហាញពីស្ថានភាពដែនជម្រកសត្វព្រៃ និងកំណត់ចំណុចសំខាន់ៗនៃការកាប់ឈើខុសច្បាប់ និងការឈូសឆាយដីព្រៃ។


សេចក្ដីផ្ដើម

ដែនជម្រកសត្វព្រៃ និងសហគមន៍

វិធីសាស្រ្ត

បញ្ហាប្រឈម ឆ្នាំ២០២១

លទ្ធផល

ចំនុចសំខាន់ៗ និងសេចក្ដីសង្ខេប

សេចក្ដីសន្និដ្ឋាន


រូបភាពទី១៨
ភាគអាគ្នេយ៍ ដែនជម្រកសត្វព្រៃ ព្រៃឡង់




រូបភាពទី១៨ បង្ហាញពីការកាប់បំផ្លាញព្រៃឈើយ៉ាងខ្លាំងក្លា និងការរិចរិលព្រៃឈើ នៅភាគអាគ្នេយ៍ នៃដែនជម្រកសត្វព្រៃ ព្រៃឡង់។ មានក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន៤ នៅជាប់នឹងព្រំប្រទល់ព្រៃឡង់៖
ក្រុមហ៊ុន Chhun Hong Rubber Better ក្រុមហ៊ុន Timas Resources ក្រុមហ៊ុន CHPB Development និងក្រុមហ៊ុន Think Biotech។

FCDM
ឧបករណ៍តាមដាន ការរំខានគម្របព្រៃឈើ

GFC
ការផ្លាស់ប្ដូរព្រៃឈើសកល

ELCs
សម្បទានដីសេដ្ឋកិច្ច

**ក្រុមហ៊ុនដែលរងការចោទប្រកាន់ពីបទ ឈូសឆាយដីព្រៃ និងការលាងឈើ៖**

- ភីអែនធី
- ធីង៉ា
- ស៊ីអស៊ីខេ១
- ស៊ីងបាយអូថេក

ព័ត៌មានភូមិសាស្ត្រ នៅខែធ្នូ ឆ្នាំ២០២១ ទិន្នន័យរូបភាពត្រូវបានទាញយកពីមន្ទីពិសោធន៍ភព (Planet Labs)។ ឧបករណ៍តាមដានការរំខានគម្របព្រៃឈើ (FCDM-រ៉ាដា) រកឃើញនៅឆ្នាំ២០២១ ដែលត្រូវបានបង្ហាញដោយស្នាមពណ៌ក្រហម ខណៈសំណុំទិន្នន័យការផ្លាស់ប្តូរព្រៃឈើសកល (GFC) ឆ្នាំ២០២១ ត្រូវបានបង្ហាញដោយស្នាមពណ៌ខៀវ។ ពណ៌ស្វាយដែលត្រួតលើគ្នា គឺជាកន្លែងដែលសំណុំទិន្នន័យទាំងពីរស្របគ្នា។ សម្បទានដីសេដ្ឋកិច្ច (ELC) ត្រូវបានបង្ហាញដោយពណ៌លឿងទុំ។

**រូបភាពទី១៩**

ភាគពាយ័ព្យ ដែនជម្រកសត្វព្រៃ ព្រៃឡង់




ក្រុមហ៊ុនស៊ីងបាយអូថេក ត្រូវបានចោទប្រកាន់ម្តងហើយម្តងទៀតថា បានឈូសឆាយដីព្រៃ និងដើមឈ្មោះដ៏មានតម្លៃរបស់សហគមន៍[21] ព្រមទាំងបំផ្លាញទួលប្រាសាទបុរាណ[22] ហើយថ្មីៗនេះ ក៏ត្រូវបានផ្សារភ្ជាប់ទៅនឹង ការលាងឈើខុសច្បាប់ចេញពីដីសម្បទាន របស់ក្រុមហ៊ុនស៊ីម៉ង KP នៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ នៅក្នុងអត្ថបទស៊ើបអង្កេតមួយរបស់ស្ថាប័ន Pulitzer Center[23]។

ក្រុមហ៊ុន បានចាប់ខ្លួនសកម្មជនបរិស្ថានបន្ថែមទៀតក្នុងពេលកន្លងទៅ[24] ហើយបើទោះបីជាមានភស្តុតាងជាច្រើនដែលប្រមូលបានពីសហគមន៍មូលដ្ឋាន និងអ្នកកាសែតក៏ដោយ[25] ក្រុមហ៊ុននៅតែបន្តបដិសេធពីការជាប់ពាក់ព័ន្ធណាមួយ ហើយត្រូវបានគូសបញ្ជាក់ដោយការស៊ើបអង្កេតរដ្ឋបាលព្រៃឈើដែលបានធ្វើឡើងកាលពីឆ្នាំ២០១៩។[26]

របាយការណ៍ដែលបានរៀបរាប់ខាងលើ "ឧក្រិដ្ឋកម្មព្រៃឈើនៅកម្ពុជា" ដែលត្រូវបានបោះពុម្ពផ្សាយដោយ គំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ពីទំនាក់ទំនងរវាង ក្រុមហ៊ុនស៊ីងបាយអូថេក និងមន្ត្រីរដ្ឋាភិបាល។[15]

រូបភាពទី១៩ បង្ហាញពីភាគពាយ័ព្យ នៃដែនជម្រកសត្វព្រៃព្រៃឡង់។

នេះជាតំបន់ដែលមានបញ្ហាមួយទៀត ដែលត្រូវបានក្រុមសកម្មជនការពារព្រៃឈើតាមដានយ៉ាងដិតដល់ ដូចទិន្នន័យជាច្រើនបានបង្ហាញ។

តំបន់នេះគឺជាប់ព្រំប្រទល់ ជាមួយសម្បទានដីសេដ្ឋកិច្ច (ELCs) ចំនួនបីគឺ៖ ក្រុមហ៊ុនស៊ីអស៊ីខេ១ (CRCK1) ក្រុមហ៊ុន ភីអែនធី (PNT) និងក្រុមហ៊ុន ធីង៉ា (Thy Nga) ដែលត្រូវបានចោទប្រកាន់ដោយសកម្មជនបរិស្ថានថា បានឈូសឆាយដីព្រៃ និងការលាងឈើតាមរយៈដីសម្បទានរបស់ពួកគេ។[27, 28, 29, 30]

ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច PNT និង Thy NGA ក៏ត្រូវបានស៊ើបអង្កេតផងដែរនៅក្នុងរបាយការណ៍ស្តីពី "ឧក្រិដ្ឋកម្មព្រៃឈើនៅកម្ពុជា"[15] ដែលជាប់ទាក់ទងជាមួយរដ្ឋាភិបាល។

# ០៦

ខណៈពេលដែលសំណុំទិន្នន័យ "ការផ្លាស់ប្តូរព្រៃឈើសកល (GFC)" បានធ្វើបច្ចុប្បន្នភាព និងចេញផ្សាយនៅក្នុងខែមេសា ឆ្នាំ២០២២ ដោយ Hansen et. al. ផ្តល់នូវការយល់ដឹងអំពីការកាប់បំផ្លាញព្រៃឈើ យើងប្រើប្រាស់វិធីសាស្រ្តផ្សេងគ្នាដើម្បីផ្តល់នូវការចង្អុលបង្ហាញអំពី ដំណើរការរិចរិលព្រៃឈើ។

ឧបករណ៍ "តាមដានការរំខានគម្របព្រៃឈើ (FCDM)" និងជាពិសេសវិធីសាស្រ្ត FCDM-រ៉ាដា ដែលបានបង្កើតឡើងដោយមជ្ឈមណ្ឌលស្រាវជ្រាវរួមនៃគណៈកម្មការអឺរ៉ុប អនុញ្ញាតឱ្យមានតាមដានដោយឯករាជ្យ លើការគ្របដណ្តប់ដោយពពក ហើយលើសពីនេះទៅទៀត ផ្តល់នូវការរកឃើញដែលអាចទុកចិត្តបានបន្ថែមទៀត នៃការជ្រើសរើសទីតាំងការកាប់ឈើ ឬតំបន់តូចៗ នៅក្នុងប្រភេទព្រៃខុសៗគ្នា ដែលលំបាកជាងកាលពីអតីតកាល។

ទិដ្ឋភាពទូទៅនៃការបាត់បង់គម្របដើមឈើ (សំណុំទិន្នន័យការផ្លាស់ប្តូរព្រៃឈើសកល) ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ក៏ដូចជាទាក់ទងនឹងការបំភាយឧស្ម័នកាបូនិក CO2 និងតំបន់ដែលរងផលប៉ះពាល់ ដោយការរិចរិលព្រៃឈើ (FCDM) សូមមើលនៅក្នុងតារាងទី១។

តំបន់រងផលប៉ះពាល់ដែលត្រូវបានគណនាដោយឧបករណ៍ FCDM មិនអាចប្រើជាសូចនាករ នៃវិសាលភាពការបាត់បង់ព្រៃឈើបានទេ។ ជាងនេះទៅទៀត វាមិនអាចជំនួស ឬប្រៀបធៀបជាមួយនឹងការរកឃើញពីសំណុំទិន្នន័យ GFC ប៉ុន្តែក៏មិនអាចបន្ថែមវាទៅជាចំនួនផ្ទៃដីដែលរងផលប៉ះពាល់បានដែរ ដោយវិធីសាស្រ្តវាស់វែងពីរប្រភេទផ្សេងគ្នា នៃការបាត់បង់ព្រៃឈើ។



## សំណុំទិន្នន័យ ដែលបានមកពីឧបករណ៍ FCDM អាចត្រូវបានប្រើជំនួស ដើម្បីបំពេញបន្ថែមលើសំណុំទិន្នន័យ GFC ដើម្បីឱ្យមានទិដ្ឋភាពរួមនៃវិសាលភាព ការបាត់បង់ព្រៃឈើនៅក្នុងដែនជម្រកសត្វព្រៃរបស់ប្រទេសកម្ពុជា។



# តួលេខនៅក្នុង ដែនជម្រកសត្វព្រៃនីមួយៗ

| | ព្រៃឡង់ | ព្រៃព្រះរកា | ព្រៃសង្ឃ សហគមន៍រុក្ខាវ៉ន /(បានប្រែប្រួល)[3] |
|---|---|---|---|
| ផ្ទៃដីសរុប | 432,380ha | 90,361ha | 30,254ha /29,490ha |
| $CO_2$ សមមូលបានបញ្ចេញ 2001[31] | 42 Mt [33] | 3 Mt [35] | 312kt /230 kt [37] |
| បាត់បង់គម្របព្រៃឈើតាំងពីឆ្នាំ 2001[32] (% នៃតំបន់សរុប) | 67,700ha [34] (13%) | 4,420ha [36] (5.7%) | 664ha (5.8%) /486ha [38] (5.4%) |
| GFC 2020 | 9,134ha [34] (2.2%) | 607ha [36] (0.78%) | 77ha (0.66%) /39ha [38] (0.44%) |
| GFC 2021 | 11,100ha [34] (2.7%) | 869ha [36] (1.1%) | 34ha /21ha [38] (0.23%) |
| FCDM 2021 | 8,822ha | 674ha | 122ha / 20ha |

**តារាងទី១៖**
ទិដ្ឋភាពទូទៅនៃទំហំសរុបរបស់តំបន់ការពារ ដែលពាក់ព័ន្ធនឹងការបាត់បង់គម្របដើមឈើ (ហិកតា) និងតំបន់រងផលប៉ះពាល់ FCDM ក៏ដូចជាសមមូល $CO_2$ ដែលបញ្ចេញទៅក្នុងបរិយាកាសដែលកើតចេញពីការបាត់បង់គម្របដើមឈើ។ ភាគរយនៃផ្ទៃដីសរុបត្រូវបានផ្តល់ឱ្យក្នុងវង់ក្រចក។ សម្រាប់ដែនជម្រកសត្វព្រៃ សង្ឃសហគមន៍រុក្ខាវ៉ន លេខទី១ ទាក់ទងនឹងផ្ទៃដីសរុបនៃដែនជម្រកសត្វព្រៃ ខណៈលេខទី២ ទាក់ទងនឹងតំបន់ដែលបានប្រែប្រួល[3] និងទី៣ មិនរាប់បញ្ចូលតំបន់ជុំវិញអាងទឹកអូរផាល ដើម្បីផ្តល់លទ្ធផលអភិរក្សបន្ថែមទៀត។

# ០៦ សេចក្តីសន្និដ្ឋាន



ព្រៃទំនាបបៃតងគ្រប់រដូវកាល របស់កម្ពុជាកំពុងប្រឈមមុខនឹងសម្ពាធជីវសាស្ត្រដែលមិនធ្លាប់មាន រួមផ្សំនិងការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះរាំងស្ងួត ទឹកជំនន់ និងការបាត់បង់ជីវៈចម្រុះយ៉ាងសម្បើម ដែលប៉ះពាល់មិនត្រឹមតែ ព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែសង្គមកម្ពុជាទាំងមូល។ ការបាត់បង់ព្រៃឈើនេះកាន់តែធ្ងន់ធ្ងរឡើងដោយគម្រោងរុករករ៉ែ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល ការពង្រីកវិស័យកសិកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលទទួលបានសិទ្ធិ កាប់ឈើ ជីកយករ៉ែ និងកសិកម្មដូចជា៖ ក្រុមហ៊ុន ស៊ីងបាយអូថេក ខូអិលធីឌី ក្រុមហ៊ុន ភីអែនធី ខូអិលធីឌី និងក្រុមហ៊ុន ធីង៉ាអភិវឌ្ឍន៍ ខូអិលធីឌី ដែលមានព្រំប្រទល់ជាប់ដែនជម្រកសត្វព្រៃ និងតែងតែ រំលោភបំពានជាប្រចាំ ដើម្បីធ្វើការកាប់ឈើក្នុងតំបន់ការពារ។ ការកាប់ឈើខុសច្បាប់បានឡើងដល់ចំនុចកំពូលនៅ ក្នុងព្រៃឡង់អំឡុងការរីករាលដាលជំងឺកូវីដ-១៩ ដោយសារការដាក់កំហិតលើការល្បាតព្រៃដូច្នេះ ហើយទើបក្រុមឈ្មួញកាប់ឈើធ្វើប្រតិបត្តិការដោយសេរី។ ជាលទ្ធផល កាលពីឆ្នាំមុន កម្ពុជាបានបាត់បង់ព្រៃឈើចំនួន ១៤៤,000ហិកតា រួមជាមួយនឹងការបាត់បង់ជីវៈចម្រុះមានទំហំមិនអាចគណនាបាន។ ពិសេសជាងនេះទៅទៀត ការបាត់បង់គម្របដើមឈើនៅក្នុងដែនជម្រកសត្វព្រៃព្រៃឡង់ មានការកើនឡើងចំនួន ២២% និងនៅក្នុងដែនជម្រកសត្វព្រៃព្រះរកា កើនឡើងចំនួន ៤៣% ខណៈដែលមានការថយចុះ នៃការបាត់បង់គម្របដើមឈើចំនួន ៤៧% ក្នុងឆ្នាំដដែល នៅក្នុងដែនជម្រកសត្វព្រៃសង្សសហគមន៍រុក្ខាវ័ន។

**មានការបាត់បង់ព្រៃឈើចំនួន ១៤៤,000ហិកតា**



**ចំនួន ២២% កើនឡើងនៅក្នុងព្រៃឡង់**

**ចំនួន ៤៣% កើនឡើងនៅក្នុងព្រៃព្រះរកា**

**ចំនួន ៤៧% កាត់បន្ថយនៅក្នុងព្រៃសង្សសហគមន៍រុក្ខាវ័ន**

ការសាងសង់បង្គោលខ្សែភ្លើង ដែលនឹងកាត់ផ្តាច់ ដែនជម្រកសត្វព្រៃព្រៃឡង់ជាពីរ គឺជាសក្ខីភាពបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាគ្មានឆន្ទៈក្នុងការទទួលស្គាល់នូវតម្លៃនៃធម្មជាតិ សង្គម និងជីវរូបវិទ្យានៃដែនជម្រកសត្វព្រៃដែលនៅសល់ចុងក្រោយរបស់ប្រទេស។ **ដូចដែលរបាយការណ៍ ពីការផ្លាស់ប្តូរ ទៅជាគំនិតផ្តួចផ្តើមជាសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ចែងថា៖**



**រូបភាពទី២០**
ការដឹកជញ្ជូនឈើខុសច្បាប់ ដោយរថយន្ត
នៅក្នុងខេត្តព្រះវិហារ។

**១៦ ធ្នូ**

"លើសពី សកម្មភាពដាច់ដោយឡែកនៃឧក្រិដ្ឋកម្ម **គំរូនៃការកាប់ឈើដោយខុសច្បាប់នៅកម្ពុជា** បង្ហាញពីបណ្តាញមួយដែលត្រូវបានរៀបចំផ្ទាល់ដោយ **ឧកញ៉ា និងមន្ត្រីសាធារណៈ** ដែលបានបង្កើតឡើង និងទទួលបានផលចំណេញពីបរិយាកាសនៃអំពើពុករលួយ និងនិទណ្ឌភាព"[15] ហើយប្រាក់ចំណេញទាំងនេះបានមកពី ផលប្រយោជន៍របស់សង្គមកម្ពុជា។

ហើយដែនជម្រកសត្វទាំងបីនេះ ជាទីជម្រកសម្រាប់ឧទ្ទិសដល់ បណ្តាលមូលដ្ឋាន នៃសហគមន៍ជាច្រើន ដែលពឹង អាស្រ័យនឹងព្រៃឈើ សកម្មជន និងមេដឹកនាំខាងជំនឿ។ សមាជិក បណ្តាញសហគមន៍ព្រៃឡង់ បណ្តាញសហគមន៍ព្រៃព្រះរកា និងព្រៃសង្ឃសហគមន៍រុក្ខាវ័ន ធ្វើការដោយមិនក្លាចនឿយហត់ ដើម្បីឃ្លាំមើល និងប្រមូលទិន្នន័យអំពី ការបាត់បង់ព្រៃឈើ ជីវចម្រុះ និងការប្រែប្រួលអាកាសធាតុ។ បំពាក់ដោយកម្មវិធីអេបព្រៃឡង់ សម្រាប់ទូរស័ព្ទស្មាតហ្វូន និងគាំទ្រដោយការឃ្លាំមើលពីផ្កាយរណប និងឧបករណ៍ដ្រូន កិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ កំពុងរួមចំណែកដល់ការយល់ដឹង កាន់តែប្រសើរឡើងអំពីការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងវិបត្តិកាលដែលកើតឡើងនៅក្នុងព្រៃឈើរបស់កម្ពុជា។ ទិន្នន័យរបស់សហគមន៍ដែលបានចងក្រងនៅក្នុងរបាយការណ៍នេះ បង្ហាញថាព្រៃឈើនៅកម្ពុជាកំពុងបាត់បង់យ៉ាងឆាប់រហ័ស ហើយបើគ្មានការអន្តរាគមន៍ជាបន្ទាន់ និងវិបត្តិកាលទេនោះ នឹងត្រូវបាត់បង់អស់មិនខានឡើយ។ ផលវិបាកនៃការបាត់បង់ព្រៃឈើ គឺជាបញ្ហាសកល ប៉ុន្តែ សហគមន៍ព្រៃឈើ ត្រូវបានទទួលរងផលប៉ះពាល់ដោយផ្ទាល់។ យោងតាមសេចក្តីថ្លែងការណ៍រួមដែលចេញផ្សាយដោយសហគមន៍ចនួនបី អាជ្ញាធរកម្ពុជាគួរតែចាត់វិធានការបន្ថែមទៀត ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មព្រៃឈើ។[39]

# ០៧



## យើងខ្ញុំទាំងអស់គ្នាជា បណ្តាញសហគមន៍ព្រៃឡង់ ព្រៃសង្ឃសហគមន៍រុក្ខាវ៉ែន និងបណ្តាញសហគមន៍ព្រៃព្រះរកា សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងបរិស្ថាន និងអាជ្ញាធរពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ មេត្តាចាត់វិធានការដូចតទៅ៖

1. យើងខ្ញុំទាំងអស់គ្នាសូមស្នើសុំដល់ រាជរដ្ឋាភិបាលកម្ពុជា មេត្តាធ្វើការត្រួតពិនិត្យ និងបញ្ឈប់ការពង្រីកតំបន់ដីសម្បទាននៅក្នុងដែនជម្រកសត្វព្រៃ។ ដូចគ្នាផងដែរសូម ដកហូតដំណែងមន្ត្រីឧទ្យានុរក្សរូបណា ដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មព្រៃឈើ ឬមិនបានបំពេញតួនាទីរបស់ខ្លួន។

2. ស្នើសុំរាជរដ្ឋាភិបាល ជាពិសេសក្រសួងបរិស្ថាន សូមបង្កើតផែនការយុទ្ធសាស្ត្រជាក់លាក់មួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងការកាប់បំផ្លាញព្រៃឈើ និងការកាប់រានដីព្រៃ សម្រាប់វិស័យកសិកម្ម ព្រមទាំងការប្រើប្រាស់កាំភ្លើងកែច្នៃ ការរបរបាញ់ និងឧបករណ៍ផ្សេងៗទៀតដែលអាចប្រើប្រាស់ក្នុងសកម្មភាពកាប់បំផ្លាញព្រៃឈើ។

3. សូមអំពាវនាវដល់រាជរដ្ឋាភិបាល មេត្តាអនុវត្តបទប្បញ្ញត្តិ និងច្បាប់ស្តីពីការការពារព្រៃឈើ។

4. សូមអំពាវនាវ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាពិភពលោក សូមចូលរួមយ៉ាងសកម្ម និងធ្វើការរួមគ្នា ដើម្បីការពារធនធានធម្មជាតិ។

5. សូមអំពាវនាវ ដល់តួអង្គអន្តរជាតិសំខាន់ៗ គួរយកចិត្តទុកដាក់ លើការបែងចែកធនធាន ដល់ប្រទេសកម្ពុជា និងបណ្តាប្រទេស ដែលរងផលប៉ះពាល់ដោយ ការកាប់បំផ្លាញព្រៃឈើ។ សូមជៀសវាងការជួញដូរឈើដែលមានប្រភពចេញពីប្រទេសកម្ពុជា។

## បន្ថែមលើការអំពាវនាវខាងលើ យើងខ្ញុំដែលជាអ្នកនិពន្ធរបាយការណ៍នេះ សំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជា៖

- លុបចោល ការហាមប្រាមសហគមន៍មូលដ្ឋាន ក្នុងការចូលទៅកាន់តំបន់ការពារព្រៃឈើ ការចុះល្បាត និងការប្រើប្រាស់ឧបករណ៍ចាប់សញ្ញាពីចម្ងាយ។ ទន្ទឹមនឹងនេះផងដែរ **សូមបង្កើតបរិយាកាសអំណោយផលសម្រាប់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ** បង្កើនការពិគ្រោះយោបល់ និងការចូលរួមរបស់ពួកគេ ក្នុងកិច្ចការងាសម្រេចចិត្ត។

- **សូមបិទអាជីវកម្មរោងម៉ាស៊ីនអារឈើទាំងអស់** ដែលនៅជាប់នឹងដែនជម្រកសត្វព្រៃ បង្កើនការត្រួតពិនិត្យ និងលុបចោលកិច្ចព្រមព្រៀងសម្បទាន ជាមួយក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច (ELCs) ដែលពាក់ព័ន្ធនឹងការលាងឈើ និងការយាយីលើ សកម្មជនបរិស្ថាន។

- **សូមស៊ើបអង្កេតទំនាក់ទំនងរវាង អាជ្ញាធរ និងឧស្សាហកម្មព្រៃឈើ។** កាត់ទោសមន្ត្រីរាជរដ្ឋាភិបាលគ្រប់រូប ដែលរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ។

[21] https://www.business-humanrights.org/es/%C3%BAltimas-noticias/cambodia-prey-lang-community-alleges-that-a-korean-owned-think-biotech-cambodia-harvests-timber-illegally-but-the-company-denies/
[22] https://www.phnompenhpost.com/national/indigenous-group-says-firm-razed-two-temples
[23] https://pulitzercenter.org/stories/large-scale-logging-cambodias-prey-lang-linked-politically-connected-mining-operation
[24] https://www.business-humanrights.org/en/latest-news/cambodia-authorities-private-security-of-think-biotech-arrest-goldman-environmental-prize-winner-three-activists/
[25] https://news.mongabay.com/2020/05/cambodian-firm-accused-of-creating-a-monopoly-in-the-timber-business/
[26] https://www.business-humanrights.org/en/latest-news/cambodia-the-forestry-administration-say-there-is-no-connection-between-think-biotech-and-alleged-illegal-logging-in-prey-lang-areas/
[27] https://news.mongabay.com/2022/06/opaque-infrastructure-plans-a-death-sentence-for-cambodias-prey-lang-wildlife-sanctuary/
[28] https://www.phnompenhpost.com/national/forest-activists-allege-logging-scheme-prey-lang
[29] https://news.mongabay.com/2020/05/they-never-intended-to-conserve-it-outcry-as-loggers-gut-cambodian-reserve/
[30] https://redd-monitor.org/2011/03/02/can-redd-protect-prey-lang-forest-in-cambodia/
[31] Harris, N.L., Gibbs, D.A., Baccini, A. et al. Global maps of twenty-first century forest carbon fluxes. Nat. Clim. Chang. 11, 234–240 (2021). https://www.nature.com/articles/s41558-020-00976-6
[32] Hansen, M. C., P. V. Potapov, R. Moore, M. Hancher, S. A. Turubanova, A. Tyukavina, D. Thau, S. V. Stehman, S. J. Goetz, T. R. Loveland, A. Kommareddy, A. Egorov, L. Chini, C. O. Justice, and J. R. G. Townshend. 2013. "High-Resolution Global Maps of 21st-Century Forest Cover Change." Science 342 (15 November): 850–53. Data available on-line from: http://earthenginepartners.appspot.com/science-2013-global-forest
[33] Global Forest Watch. "Forest-related greenhouse gas emissions in Prey Lang wildlife sanctuary". Accessed on 07/07/2022 from www.globalforestwatch.org
[34] Global Forest Watch. "Tree cover loss in Prey Lang wildlife sanctuary". Accessed on 07/07/2022 from www.globalforestwatch.org
[35] Global Forest Watch. "Forest-related greenhouse gas emissions in Preah Rokar wildlife sanctuary". Accessed on 07/07/2022 from www.globalforestwatch.org
[36] Global Forest Watch. "Tree cover loss in Preah Rokar wildlife sanctuary". Accessed on 07/07/2022 from www.globalforestwatch.org
[37] Global Forest Watch. "Forest-related greenhouse gas emissions in Sorng Rokha Vorn wildlife sanctuary". Accessed on 07/07/2022 from www.globalforestwatch.org
[38] Global Forest Watch. "Tree cover loss in Sorng Rokha Vorn wildlife sanctuary". Accessed on 07/07/2022 from www.globalforestwatch.org
[39] Joint statement of PLCN, PFCN, and MCF: Illegal Deforestation and Land Clearance in Prey Lang, Prey Preah Roka, and Monk Community Forest.


**សម្រាប់ព័ត៌មានបន្ថែម**
**សូមទំនាក់ទំនងសមាជិកសហគមន៍ ដូចខាងក្រោម៖**

### បណ្តាញសហគមន៍ព្រៃឡង់ (PLCN)

លោក ឯក សុវណ្ណា 097 644 9998
លោក ស្វាយ សុង 071 451 9465
លោក ស្រី ថី 099 637147
លោក ខេម សុឃី 085 473 157
លោក ម៉ិញ នី 096 300 2762
លោក ហឿន សុភាព 012 373 441
អ្នកស្រី ឈាង លី 096 668 0673
លោក ខេង ខូ 071 451 9463

### បណ្តាញសហគមន៍ព្រៃព្រះរកា (PFCN)

លោក ស៊ុត សាវ៉ន 0975080302
លោក ឈួន ឃីម 0889258950

### ព្រៃសង្ឃសហគមន៍រុក្ខាវ័ន (MCF)

ព្រះតេជគុណ ថូ ធូរស់ 095542194
លោក សា ថ្លៃ 089446220

**រូបភាពគម្រប់ខាងមុខ**
គល់ឈើដែលកាប់ផ្តួលដោយខុសច្បាប់ ត្រូវបានរាយការណ៍ នៅខេត្តព្រះវិហារ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១។

**រូបភាពគម្រប់ខាងក្រោយ**
ដើមឈើប្រណីតមួយដើមត្រូវបានរាយការណ៍ នៅក្នុងខេត្តកំពង់ធំ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១។

ការបោះពុម្ពផ្សាយនេះ ត្រូវបានផលិតឡើងដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពី សហភាពអឺរ៉ុប (European Union)។ ខ្លឹមសាររបស់របាយការណ៍នេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ CEEJA ដោយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ សហភាពអឺរ៉ុបនោះឡើយ។ ព័ត៌មានដែលមាននៅក្នុងឯកសារនេះ គឺជាកម្មសិទ្ធិបញ្ញារបស់ CEEJA។

## សូមស្វាគមន៍សម្រាប់ការប្រើប្រាស់ ការបោះពុម្ពផ្សាយ និងការចែកចាយឯកសារនេះឡើងវិញ ដែលត្រូវបានផ្តល់ជូននូវប្រភពឯកសារយោង។

CEEJA សូមថ្លែងអំណរគុណចំពោះ មជ្ឈមណ្ឌលស្រាវជ្រាវរួមនៃគណៈកម្មការអឺរ៉ុប ដែលបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសដោយចែករំលែកនូវការរំខានគម្រប់ព្រៃឈើ ដោយប្រើប្រាស់នូវឧបករណ៍ FCDM អ្នកហាត់ការមកពីសាកលវិទ្យាល័យ Copenhagen និងអ្នករួមការងារទាំង អស់ដែលបានផ្តល់ជំនួយរបស់ពួកគេដោយស្ម័គ្រចិត្ត។ របាយការណ៍នេះ មិនអាចធ្វើឡើងបានឡើយបើគ្មានការរួមចំណែករបស់ពួកគេ។

កម្មវិធីអេបព្រៃឡង់ត្រូវបានបង្កើតឡើងដោយផ្អែកលើ Sapelli៖ គម្រោង open-source ដែលសម្របសម្រួលការប្រមូលទិន្នន័យឆ្លងភាសា ឬអក្ខរកម្មតាមរយៈការកំណត់រូបភាពបង្ហាញផ្លូវសម្រាប់អ្នកប្រើប្រាស់។ សម្រាប់ព័ត៌មានបន្ថែម៖ http://www.sapelli.org/

រូបភាពទាំងអស់ គឺជាកម្មសិទ្ធិបញ្ញារបស់សហគមន៍។ ផែនទីទាំងអស់ត្រូវបានធ្វើឡើងដោយកម្មវិធី ArcGIS Pro 2.7.1.

រចនាក្រាហ្វិច និងរូបភាពដ្យាក្រាមដោយ Carolina Salassa (carolina.salassa@outlook.it)។

ការងារនេះត្រូវបានអនុញ្ញាតនៅក្រោម Creative Commons Attribution-NonCommercial-ShareAlike 4.0 International Licence.
ដើម្បីមើលច្បាប់ចម្លងនៃអាជ្ញាប័ណ្ណនេះ សូមចូលទៅកាន់៖ https://creativecommons.org/licenses/by-nc-sa/4.0/



CEEJA
PREY LANG
IT'S OUR FOREST TOO
PFCN
Monk's Community Forestry Cambodia